# កិច្ចព្រមព្រៀងសន្តិភាព

របបនៅភ្នំពេញ ថ្លែងជាបំណងរកប្រយោជន៍ថា កិច្ចព្រមព្រៀងសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ វាស្លាប់បាត់ទៅហើយ តែសំដីនេះ ពួកនេះភ្លេចគិតថា កិច្ចព្រមព្រៀងនេះ ជាប្រភពគ្រឹះនៃរដ្ឋធម្មនុញ្ញខ្មែរសព្វថ្ងៃ ដែលជាសសរទ្រូង នៃរបបដឹកនាំជាតិខ្មែរ។ ជារៀងរហូតមក ពួកអ្នកដឹកនាំផ្តាច់ការ មិនដែលគោរពរដ្ឋធម្មនុញ្ញជាតិ ដូច្នេះ វាជាការពិត ពួកនេះអាចនិយាយបានថា កិច្ចព្រមព្រៀងសន្តិភាព វាស្លាប់ពិតមែន។ ប៉ុន្តែ បើពួកខ្លួន មិនទុកកិច្ចព្រមព្រៀងសន្តិភាពថា នៅមានសុពលភាពគឺពួកនេះ ដកខ្លួនចេញដោយខ្លួនឯងពីដំណើរការនៃរដ្ឋធម្មនុញ្ញ ដូច្នេះ ពួកនេះបង្កើត របបថ្មីនៅក្រៅពីរបបដឹកនាំជាតិ ដែលជារបបខុសច្បាប់ ដែលយក ច្បាប់គណបក្សរបស់ខ្លួនមកអនុវត្តនៅក្នុងស្ថាប័នជាតិ យកអំណាចតុលាការធ្វើជាអាវុធនយោបាយ សំរាប់គាបត្បៀតសេរីភាព នៃប្រជាពលរដ្ឋ និង សង្កិតសង្កិនដៃគូនយោបាយ ដែលជាគណបក្សប្រឆាំង។ មួយវិញទៀត ត្រូវដឹងថា ដានភ្លឺ នៃសភាពជាធរមានរបស់កិច្ចព្រមព្រៀងសន្តិភាពនៅស្រុកខ្មែរ គឺ វត្តមាន នៃអ្នកសង្កេតការណ៍សិទ្ធិមនុស្សរបស់ អ.ស.ប. ប្រចាំនៅកម្ពុជា ដែលជា ការបង្កើតនៅក្នុងក្របខណ្ឌ នៃកិច្ចព្រមព្រៀងសន្តិភាព ដែលជា អ្នកធ្វើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសិទ្ធិមនុស្ស។ វត្តមាននេះឯង ដែលជា រន្ទះមាត់ចំពោះរបបនៅភ្នំពេញលើឆាកអន្តរជាតិ ស្តីពីការបំពានសិទ្ធិនៅកម្ពុជា៕